ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្ដាល**

សំណុំរឿងរដ្ឋប្បវេណីលេខ ៥៩៤

ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២

**សាលក្រមលេខ:០៥៣(ឧ)**

ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២២

*តាងនាមប្រជារាស្ត្រខ្មែរ*

**សាលាដំបូងខេត្តកណ្ដាល**

បានបញ្ចប់ការទាញហេតុផលផ្ទាល់មាត់នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ ២០២២ និងប្រកាសាលក្រម នៅថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ២០២២

ដោយមានសមាសភាព:

-លោក [redacted] ចៅក្រម

-លោក [redacted] ក្រឡាបញ្ជី

-ដើមចោទឈ្មោះ [redacted] **ឡាយខាន់ ហៅ** [redacted] **សុទ្ធារី** ភេទស្រី កើតឆ្នាំ១៩៥៤ ជនជាតិខ្មែរ មាន អាសយដ្ឋានបច្ចុប្បន្ននៅ [redacted] ។

មានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិអោយដើមចោទ។

-ចុងចម្លើយឈ្មោះ [redacted] **សាន** ភេទប្រុស និងប្រពន្ធឈ្មោះ [redacted] **សុខា** ភេទស្រី ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅ [redacted]។

## <u>អង្គហេតុ និងចំណុចវិវាទ</u>

**១-ខ្លឹមសារនៃសាលក្រមដែលទាមទារដោយដើមចោទ:**

១.១-បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ [redacted] សាន និងឈ្មោះ [redacted] សុខា សងប្រាក់ដើមចំនួន ៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិក មកភាគីដើមចោទ។

១.២-បង្គាប់ឲ្យភាគីសហចុងចម្លើយបង់ការប្រាក់ចំនួន ០២%(ពីរ) ភាគរយក្នុងមួយខែ លើប្រាក់ដើមចំនួន ៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិក ព្រមទាំងប្រាក់ពិន័យនៃការយឺតយ៉ាវក្នុងការសងការប្រាក់ប្រចាំខែចំនួន ០២%(ពីរ) ភាគរយ គិតចាប់ពី ខែកុម្ភៈ ឆ្នាំ២០២១ រហូតដល់សងប្រាក់ដើមគ្រប់ចំនួន។



Scanned with CamScanner

១.៣-បង្គាប់ឲ្យភាគីសហចុងចម្លើយសងសេវាកម្មផ្នែកច្បាប់ចំនួន ៤០(សែសិប) លានរៀល និងប្រាក់ជំងឺចិត្ត និងការខាតបង់ពេលវេលាចំនួន ៤០(សែសិប) លានរៀល ឲ្យមកភាគីដើមចោទ។

១.៤-ប្រាក់ប្រដាប់ក្ដីជាបន្ទុកភាគីចុងចម្លើយ។

១.៥-ការទាមទារចំណុចទី១នេះប្រកាសអនុវត្តជាបណ្ដោះអាសន្ន។

**២-ការពន្យល់ត្រួសៗអំពីរឿងក្ដី:**

កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៦ ភាគីសហចុងចម្លើយបានខ្ចីប្រាក់ចំនួន ៣០.០០០(បីម៉ឺន) ដុល្លារអាមេរិក ពីភាគីដើមចោទ ដែលភាគីទាំងពីរបានព្រមព្រៀងគ្នាអំពីការប្រាក់ប្រចាំខែចំនួន ១,៥%(មួយក្បៀសប្រាំភាគរយ) ដែលស្មើនិងចំនួន ៤៥០(បួនរយហាសិប) ដុល្លារអាមេរិកក្នុងមួយខែ ហើយភាគីសហចុងចម្លើយសន្យាសងប្រាក់ដើមសរុប ក្នុងរយៈពេល១២ខែ គិតចាប់ពីថ្ងៃទទួលប្រាក់ពីភាគីដើមចោទ (គឺថ្ងៃទី២០ខែឧសភា ឆ្នាំ២០១៦)។ ដើម្បីធានាចំពោះការសងបំណុល ភាគីសហចុងចម្លើយបានដាក់បញ្ចាំអចលនវត្ថុ(ដី និង ផ្ទះ) មួយកន្លែង មានលិខិតបញ្ជាក់កម្មសិទ្ធិដីធ្លីលេខ ០២៣/១៤ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៤ របស់លោកមេឃុំវិហារសួគ៌ ដែលមានបណ្ដោយ ៩០ម៉ែត្រ និងទទឹង ១៣,៥ម៉ែត្រ+ ១១ម៉ែត្រ មានទីតាំងស្ថិតនៅភូមិវិហារសួគ៌ត្បូង ឃុំវិហាសួគ៌ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល។

កាលបរិច្ឆេទកំណត់នៃការសងប្រាក់ដើមចំនួន ៣០.០០០$ (បីម៉ឺនដុល្លារអាមេរិក) ដែលបានខ្ចីឲ្យគ្រប់ចំនួន បានមកដល់ ប៉ុន្តែភាគីសហចុងចម្លើយ ពុំបានសងប្រាក់ដើមមកឲ្យភាគីដើមចោទស្របតាមការកំណត់ក្នុងកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៦ នោះទេ។

នៅថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៨ ភាគីសហចុងចម្លើយបានខ្ចីប្រាក់ពីភាគីដើមចោទចំនួន ១០.០០០$(មួយម៉ឺនដុល្លារអាមេរិក) បន្ថែមដោយព្រមព្រៀងគ្នាអំពីការប្រាក់ចំនួន ០២%(ពីរភាគរយ) ក្នុងមួយខែ នៃប្រាក់ដែលមិនទាន់សងនិងប្រាក់ខ្ចីបន្ថែមនេះ ហើយយល់ព្រមដាក់បញ្ចាំដីមួយកន្លែង បន្ថែមទៀត ដែលមានបណ្ដោយ ៩៦+៨៤ ម៉ែត្រ និងទទឹង ៩៤+៩២ ម៉ែត្រ ដែលមានទីតាំងស្ថិតនៅភូមិព្រៃធំ ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល មានលិខិតបញ្ជាក់ប្រវត្តិដីធ្លីលេខ ១៣២/១៨ វហ.ស ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៩ ចេញដោយសាលាឃុំវិហារសួគ៌ ស្រុកខសាច់កណ្ដាល ខេត្តកណ្ដាល ដើម្បីធានាសិទ្ធិលើបំណុលចំពោះភាគីដើមចោទបន្ថែមទៀត ។



Scanned with CamScanner

ក្រោយពីបានទទួលបានប្រាក់កម្ចីទាំងពីរលើករួចមក ភាគីសហចុងចម្លើយមិនបានបំពេញកាតព្វកិច្ចក្នុងការសងប្រាក់តាមការសន្យានោះឡើយ។

នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ ភាគីដើមចោទបានដាក់ពាក្យបណ្ដឹងនៅសាលាឃុំវិហារសួគ៌ ដើម្បីដោះស្រាយ និងសម្របសម្រួលរបស់លោកមេឃុំវិហារសួគ៌ ដោយភាគីសហចុងចម្លើយបានទទួលស្គាល់ថា ខ្លួនពិតនៅជំពាក់ប្រាក់ភាគីដើមចោទចំនួន ៤០.០០០$(បួនម៉ឺនដុល្លារអាមេរិក) ព្រមទាំងប្រាក់ចំនួន ២%(ពីរភាគរយ) ដែលមិនបានសងចាប់ពីខែកុម្ភៈ ឆ្នាំ២០២១ ប្រាកដមែន តែសហចុងចម្លើយនៅតែពុំព្រមអនុវត្ត ទើបដើមចោទដាក់ពាក្យបណ្ដឹងមកសាលាដំបូងខេត្តកណ្ដាល តែម្ដង។

**៣-ការអះអាងរបស់ភាគី ៖**

-ដើមចោទឈ្មោះ [redacted] ឡាយខាន់ ហៅ [redacted] សុទ្ធារី បានចូលមកធ្វើការអះអាងថា៖ ខ្លួនប្ដឹងសុំឲ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារ:

១-បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ [redacted] សាន និងឈ្មោះ [redacted] សុខា សងប្រាក់ដើមចំនួន ៤០.០០០$(បួនម៉ឺន) ដុល្លារអាមេរិក មកភាគីដើមចោទ។

២-បង្គាប់ឲ្យភាគីសហចុងចម្លើយបង់ការប្រាក់ចំនួន ០២%(ពីរ) ភាគរយក្នុងមួយខែ លើប្រាក់ដើមចំនួន ៤០.០០០$ (បួនម៉ឺន) ដុល្លារអាមេរិក ព្រមទាំងប្រាក់ពិន័យនៃការយឺតយ៉ាវក្នុងការសងការប្រាក់ប្រចាំខែចំនួន ០២%(ពីរ) ភាគរយ គិតចាប់ពីខែកុម្ភៈ ឆ្នាំ២០២១ រហូតដល់សងប្រាក់ដើមគ្រប់ចំនួន។

៣-បង្គាប់ឲ្យភាគីសហចុងចម្លើយសងសេវាកម្មផ្នែកច្បាប់ចំនួន ៤០(សែសិប) លានរៀល និងប្រាក់ជំងឺចិត្ត និងការខាតបង់ពេលវេលាចំនួន ៤០(សែសិប) លានរៀល ឲ្យមកភាគីដើមចោទ។

៤-ប្រាក់ប្រដាប់ក្ដីជាបន្ទុកភាគីចុងចម្លើយ។

៥-ការទាមទារចំណុចទី១នេះប្រកាសអនុវត្តជាបណ្ដោះអាសន្ន។

*__ដោយមូលហេតុថា៖__* កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៦ ភាគីសហចុងចម្លើយបានខ្ចីប្រាក់ចំនួន ៣០.០០០$(បីម៉ឺន) ដុល្លារអាមេរិក ពីភាគីដើមចោទ ដែលភាគីទាំងពីរបានព្រមព្រៀងគ្នាអំពីការប្រាក់ប្រចាំខែចំនួន ១,៥%(មួយក្បៀសប្រាំភាគរយ) ដែលស្មើនិងចំនួន ៤៥០$(បួនរយហាសិប) ដុល្លារអាមេរិក ក្នុងមួយខែ ហើយភាគីសហចុងចម្លើយសន្យាសងប្រាក់ដើមសរុប ក្នុងរយៈពេល១២ខែ គិតចាប់ពីថ្ងៃទទួលប្រាក់ពីភាគីដើមចោទ (គឺថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៦)។



Scanned with CamScanner

ដើម្បីធានាចំពោះការសងបំណុល ភាគីសហចុងចម្លើយបានដាក់បញ្ចាំអចលនវត្ថុ(ដីនិង ផ្ទះ) មួយកន្លែង មានលិខិតបញ្ជាក់កម្មសិទ្ធិដីធ្លីលេខ ០២៣/១៤ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៤ របស់លោកមេឃុំវិហារសួគ៌ ដែលមានបណ្តោយ ៩០ម៉ែត្រ និងទទឹង ១៣,៥ម៉ែត្រ+ ១១ម៉ែត្រ មានទីតាំងស្ថិតនៅភូមិវិហារសួគ៌ត្បូង ឃុំវិហាសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។

កាលបរិច្ឆេទកំណត់នៃការសងប្រាក់ដើម ៣០.០០០$ (បីម៉ឺនដុល្លារអាមេរិក) ដែលបានខ្ចីឲ្យគ្រប់ចំនួនបានមកដល់ ប៉ុន្តែភាគីសហចុងចម្លើយ ពុំបានសងប្រាក់ដើមមកឲ្យភាគីដើមចោទ ស្របតាមការកំណត់ក្នុងកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៦ នោះទេ។

នៅថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៨ ភាគីសហចុងចម្លើយបានខ្ចីប្រាក់ពីភាគីដើមចោទចំនួន ១០.០០០(មួយម៉ឺនដុល្លារអាមេរិក) បន្ថែមដោយព្រមព្រៀងគ្នាអំពីការប្រាក់ចំនួន ០២%(ពីរភាគរយ)ក្នុងមួយខែ នៃប្រាក់ដែលមិនទាន់សងនិងប្រាក់ខ្ចីបន្ថែមនេះ ហើយយល់ព្រមដាក់បញ្ចាំដីមួយកន្លែងបន្ថែមទៀត បណ្តោយ ៩៦+៨៤ ម៉ែត្រ និងទទឹង ៩៤+៩២ ម៉ែត្រ ដែលមានទីតាំងស្ថិតនៅភូមិព្រៃធំ ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល មានលិខិតបញ្ជាក់ប្រវត្តិដីធ្លីលេខ ១៣២/១៨ វហ.ស ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៩ ចេញដោយសាលាឃុំវិហារសួគ៌ ដើម្បីធានាសិទ្ធិលើបំណុលចំពោះភាគីដើមចោទបន្ថែមទៀត។

ក្រោយពីបានទទួលបានប្រាក់កម្ចីទាំងពីរលើករួចមក ភាគីសហចុងចម្លើយមិនបានបំពេញកាតព្វកិច្ចក្នុងការសងប្រាក់តាមការសន្យានោះឡើយ។

នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ ភាគីដើមចោទបានដាក់ពាក្យបណ្តឹងនៅសាលាឃុំវិហារសួគ៌ដើម្បីដោះស្រាយ និងសម្របសម្រួលរបស់លោកមេឃុំវិហារសួគ៌ ដោយភាគីសហចុងចម្លើយបានទទួលស្គាល់ថា ខ្លួនពិតនៅជំពាក់ប្រាក់ភាគីដើមចោទចំនួន ៤០.០០០ (បួនម៉ឺនដុល្លារអាមេរិក) ព្រមទាំងប្រាក់ចំនួន ២%(ពីរភាគរយ) ដែលមិនបានសងចាប់ពីខែកុម្ភៈ ឆ្នាំ២០២១ ប្រាកដមែន

-ចុងចម្លើយឈ្មោះ [redacted] សាន បានចូលមកអះអាងថា៖ ខ្លួនពិតជាបានចងការប្រាក់ពីដើមចោទឈ្មោះ [redacted] ឡាយខាន់ ហៅ [redacted] សុទ្ធារី ចំនួន ៣០.០០០(បីម៉ឺនដុល្លារអាមេរិក) ពិតប្រាកដមែន និងបានធ្វើកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៦ និងយល់ព្រមឲ្យការប្រាក់តាមកិច្ចសន្យានោះទាំងអស់។ លុះដល់ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៨ ខ្លួនបានខ្ចីប្រាក់ចំនួន ១០.០០០(មួយម៉ឺនដុល្លារអាមេរិក) សរុបទាំងអស់ ៤០.០០០(បួនម៉ឺនដុល្លារអាមេរិក)។ ការខ្ចីនេះខ្លួនបានអនុវត្តឲ្យអាត្រាការប្រាក់ទៅភាគីដើមចោទរហូតមក ទើបតែអាក់ខាន ពីខែកុម្ភៈ ឆ្នាំ២០២១ ដោយមូលហេតុ



Scanned with CamScanner

ជំងឺកូវីដ១៩ បណ្តាលឲ្យខ្លួនពុំបានផ្តល់ប្រាក់ឲ្យភាគីដើមចោទតាមកិច្ចសន្យា។ ចំពោះរឿងនេះ ខ្លួនសុំសងប្រាក់ដើមទៅដើមចោទ នឹងសុំឲ្យដើមចោទជួញទិញដីរបស់ខ្លួន ហើយខ្លួននឹងបានទូរទាត់ប្រាក់ដើមឲ្យគ្រប់ចំនួន ចំពោះការប្រាក់ សេវាផ្នែកច្បាប់ និងសំណងជំងឺចិត្តផ្សេងៗសុំឲ្យដើមចោទលះបង់ចោល។

-ចុងចម្លើយឈ្មោះ [redacted] សុខា បានឯកភាពលើសេចក្តីអះអាងរបស់ឈ្មោះ [redacted] សាន ជាប្តីទាំងស្រុង

៤-*<u>ចំណុចវិវាទះ</u>*

-ប្រាក់សេវាផ្នែកច្បាប់ចំនួន ៨០.០០០.០០០ (សែសិបលានរៀល) ប្រាក់ជំងឺចិត្ត និងការខាតបង់ពេលវេលាចំនួន ៨០.០០០.០០០ (សែសិបលានរៀល) និងអាត្រាការប្រាក់ចំនួន ០២%(ពីរភាគរយ) និងប្រាក់ប្រដាប់ក្តី។

៥-*<u>ចំណុចគ្មានវិវាទ</u>* ះ

-ប្រាក់ដើមចំនួន ៨០.០០០ (បួនម៉ឺនដុល្លារអាមេរិក)។

## សំអាងហេតុ

១-តាមពាក្យបណ្តឹងចុះថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០២២ របស់ដើមចោទឈ្មោះ [redacted] ឡាយខាន់ ហៅ [redacted] សុទ្ធារី គឺមានលក្ខណៈត្រឹមត្រូវតាមមាត្រា ៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

២.តាមការអះអាងរបស់មេធាវីតំណាងដោយអាណត្តិអោយដើមចោទថាៈ ខ្លួននៅតែទាមទារដូចក្នុងពាក្យបណ្តឹង ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២២ និងសេចក្តីថ្លែងការណ៍ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២២ ទុកជាបានការដដែល។ ភាគីសហាចុងចម្លើយបានទទួលស្គាល់ប្រាក់ដែលខ្ចីដើមចោទចំនួន ៣០.០០០$(បីម៉ឺនដុល្លារអាមេរិក) ដែលមានកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៦ និងយល់ព្រមឲ្យការប្រាក់តាមកិច្ចសន្យានោះទាំងអស់។ លុះដល់ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៨ សហាចុងចម្លើយបានធ្វើការខ្ចីប្រាក់ ភាគីដើមចោទចំនួន ១០.០០០$ (មួយម៉ឺនដុល្លារអាមេរិក) សរុបចំនួន ៤០.០០០$ (បួនម៉ឺនដុល្លារអាមេរិក) ព្រមទាំងការប្រាក់ចំនួន ២%(ពីរភាគរយ) ដែលមិនបានសងចាប់ពីខែកុម្ភៈ ឆ្នាំ២០២១។

៣-សហាចុងចម្លើយឈ្មោះ [redacted] សាន និងប្រពន្ធឈ្មោះ [redacted] សុខា ទទួលស្គាល់ថាខ្លួនពិតជាបានខ្ចីប្រាក់ពីដើមចោទ ចំនួន៣០.០០០$(បីម៉ឺនដុល្លារអាមេរិក) ដោយមានកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២០ ខែ ឧសភា ឆ្នាំ២០១៦ ភាគីទាំងពីរបានព្រមព្រៀងគ្នាអំពីអាត្រាការប្រាក់ចំនួន

១,៥%(មួយក្បៀសប្រាំភាគរយ) ដែលស្មើនិងចំនួន ៤៥០(បួនរយហាសិបដុល្លារអាមេរិក) ក្នុងមួយខែ ការខ្ចីនោះមានរយៈពេល ១២ខែ ដោយ គិចចាប់ពីថ្ងៃទទួលប្រាក់ពីភាគីដើមចោទ តែសហចុងចម្លើយពុំបានអនុវត្តនោះទេ។ និងនៅថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៨ ភាគីសហចុងចម្លើយបានខ្ចីប្រាក់ពីភាគីដើមចោទចំនួន ១០.០០០$(មួយម៉ឺនដុល្លារអាមេរិក) បន្ថែមដោយព្រមព្រៀងគ្នាអំពីការប្រាក់ចំនួន ០២%(ពីរភាគរយ) ក្នុងមួយខែ នៃប្រាក់ដែលមិនទាន់សងនិងប្រាក់ខ្ចីបន្ថែមនេះ គឺសរុបទាំងអស់មានចំនួន ៤០ ០០០$ (បួនម៉ឺន)ដុល្លារអាមេរិក។ តុលាការទទួលស្គាល់ថា មានអង្គហេតុដែលអះអាងដោយដើមចោទ ដោយផ្អែកតាមមាត្រា ១២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ កិច្ចសន្យានេះជាកិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ជាមួយការប្រាក់ ផ្អែកតាមមាត្រា ៥៧៨ ,មាត្រា ៥៨៣ និងមាត្រា ៥៨៤ នៃក្រមរដ្ឋប្បវេណី។

៤-ផ្អែកតាមកាលបរិច្ឆេទខ្ចីប្រាក់ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៦ ឃើញថា រយៈពេលខ្ចីប្រាក់គឺ ១២ ខែ ដោយមានប្រាក់ដើមចំនួន ៣០.០០០$ (បីម៉ឺនដុល្លារអាមេរិក) មានអាត្រាការប្រាក់ចំនួន ១,៥%(មួយក្បៀសប្រាំភាគរយ) ដែលកិច្ចសន្យានេះ សហចុងចម្លើយពុំបានសងប្រាក់ដើមមកឲ្យភាគីដើមចោទ ស្របតាមការកំណត់ក្នុងកិច្ចសន្យាខ្ចីប្រាក់។ នៅថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៨ ភាគីសហចុងចម្លើយបានខ្ចីប្រាក់ពីភាគីដើមចោទចំនួន ១០.០០០$(មួយម៉ឺនដុល្លារអាមេរិក) បន្ថែម ដោយព្រមព្រៀងគ្នាអំពីអាត្រាការប្រាក់ចំនួន ២%(ពីរភាគរយ) ក្នុងមួយខែនៃប្រាក់ដែលមិនទាន់សង និងប្រាក់ខ្ចីបន្ថែម ក្រោយពេលទទួលបានប្រាក់ទាំងពីរលើករួចមក ភាគីសហចុងចម្លើយមិនបានបំពេញកាតព្វកិច្ចក្នុងការសងប្រាក់តាមការសន្យានោះឡើយ។

៥-យោងតាមមាត្រា ៥៩៤ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ( ពេលវេលានៃការសង បានចែងថា ប្រសិនបើភាគីបានកំណត់កាលបរិច្ឆេទនៃការសង អ្នកខ្ចីមិនអាចទាមទារឲ្យសងវត្ថុដែលជាកម្មវត្ថុបានឡើយ រហូតដល់ពេលកំណត់ត្រូវសង តាមកាលបរិច្ឆេទនៃកិច្ចសន្យា)។ ប៉ុន្តែបញ្ញត្តិមិនត្រូវបានយកមកអនុវត្តឡើយ ក្នុងករណីដែលហេតុដែលបានកំណត់ក្នុងមាត្រា ៣៣១ (ការបាត់បង់ផលប្រយោជន៍នៃការកំណត់ពេលវេលា) នៃក្រមនេះបានកើតឡើង។

៦-ផ្អែកតាមកិច្ចសន្យាខ្ចីប្រាក់ ៤០.០០០ $(បួនម៉ឺនដុល្លារអាមេរិក) មានអត្រាការប្រាក់ ០២% ក្នុងមួយខែ ដើមចោទ នឹងសហចុងចម្លើយបានព្រមព្រៀងគ្នាអំពីការប្រាក់នេះ គិតចាប់ពីខែកុម្ភៈ ឆ្នាំ២០២១ រហូតដល់បង់ប្រាក់ដើមគ្រប់ចំនួន ដូច្នេះតុលាការសម្រេចពីអត្រាការប្រាក់ផ្អែកតាមកិច្ចសន្យាខ្ចីប្រាក់។

៧-ចំពោះការទាមទារសំណងជំងឺចិត្តខាតបង់ពេលវេលាចំនួន ៤០.០០០.០០០ (សែសិបលានរៀល)

និងសេវាផ្នែកច្បាប់ចំនួន ៤០.០០០.០០០(សែសិបលានរៀល) ដើមចោទបានបង្ហាញច្បាស់លាស់ពីទំហំនៃការខូចខាត ដូច្នេះតុលាការពិចារណា ឃើញថាពិតជាមានការខូចខាតដែលកើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ចរបស់សហចុងចម្លើយពិតប្រាកដមែន។ តុលាការពិចារណាសម្រេចពីសេវាផ្នែកច្បាប់ នឹងសំណងការខូចខាតក្នុងកម្រិតសមរម្យ ដោយផ្អែកតាមមាត្រា ៣៩៨ និងមាត្រា ៤០០ នៃក្រមរដ្ឋប្បវេណី។

៨-ចំពោះការសុំអនុវត្តបណ្ដោះអាសន្ន តុលាការអាចពិចារណាបានទៅលើប្រាក់ដើម ដោយសារជាការទាមទារសិទ្ធិលើទ្រព្យសម្បត្តិ និងមានភាពចាំបាច់ ចៀសវាងការអូសបន្លាយពេលវេលាដោយគូភាគីបានទទួលស្គាល់រួចហើយ ផ្អែកតាមមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

៩-យោងតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយដែលជាភាគីចាញ់ក្ដី។

## សេចក្ដីសន្និដ្ឋាន

-តុលាការទទួលស្គាល់ការទាមទាររបស់ដើមចោទ ចំពោះប្រាក់ដើម។

-ការប្រាក់ត្រូវសម្រេចដោយផ្អែកតាមកិច្ចសន្យាខ្ចីប្រាក់។

-សំណងការខូចខាតត្រូវសម្រេចតាមសភាពសមរម្យ។

-ការអនុវត្តបណ្ដោះអាសន្ន អាចធ្វើទៅលើប្រាក់ដើម។

## សេចក្ដីសម្រេចបញ្ចប់

**១**-ទទួលពាក្យបណ្ដឹងចុះថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០២២ របស់ដើមចោទទុកជាត្រឹមត្រូវតាមច្បាប់។

**២**.បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ [redacted] សាន និងប្រពន្ធឈ្មោះ [redacted] សុខា សងប្រាក់មកដើមចោទឈ្មោះ [redacted] ឡាយខាន់ ហៅ [redacted] សុគន្ធារី នូវះ

២.១-ប្រាក់ដើមចំនួន ៤០.០០០ $(បួនម៉ឺនដុល្លារអាមេរិក)។

២.២-ការប្រាក់ ២% ក្នុងមួយខែ គិតចាប់ពីខែកុម្ភៈ ឆ្នាំ២០២១ រហូតដល់សងគ្រប់ចំនួន។

២.៣-សងប្រាក់ថ្លៃសំណងជំងឺចិត្ត និងការខូចខាតពេលវេលា និងសេវាកម្មច្បាប់សរុបចំនួន២០ ០០០ ០០០រ(ម្ភៃលាន)រៀល ឲ្យដើមចោទឈ្មោះ [redacted] ឡាយខាន់ ហៅ [redacted] សុគន្ធារី ។

២.៤-សាលក្រមនេះអាចអនុវត្តជាបណ្តោះអាសន្នត្រង់ចំណុចទី២.១ នៃសេចក្តីសម្រេច

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុកភាគីចុងចម្លើយ។

-ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ថ្ងៃព្រហស្បតិ៍ ១០កើត ខែកក្តិក ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ខេត្តកណ្តាល,ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២២

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម។

ថ្ងៃព្រហស្បតិ៍ ១០កើត ខែកក្តិក ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ខេត្តកណ្តាល,ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២២

**បានឃើញ**
**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]